ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ព្រឹត្តិបត្រស្ថិតិ
# សេដ្ឋកិច្ច និងហិរញ្ញវត្ថុ
# ប្រចាំត្រីមាសទី៤ ឆ្នាំ២០១៧

## អគ្គនាយកដ្ឋានគោលនយោបាយ
## ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ខែកុម្ភៈ ឆ្នាំ២០១៨

## មាតិកា


I. សេចក្តីអធិប្បាយសង្ខេប ..... 1

II. ស្ថិតិសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ..... 5

**១. សូចនាករសេដ្ឋកិច្ចសំខាន់ៗ** ..... 5

**២. សូចនាករតាមវិស័យ** ..... 7

២.១. សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ ..... 7

២.៣. អត្រាប្តូរប្រាក់ ..... 8

២.៤. ហិរញ្ញវត្ថុសាធារណៈ ..... 9

២.៥. ឥណទាន និងរូបិយវត្ថុ ..... 13

២.៦. វិស័យពាណិជ្ជកម្ម ..... 14

២.៧. ការវិនិយោគឯកជន ..... 18

២.៨. វិស័យទេសចរណ៍ ..... 19

២.៩. វិស័យសំណង់ ..... 20

**៣. ថ្លៃទំនិញសំខាន់ៗ និងអត្រាប្តូរប្រាក់លើទីផ្សារអន្តរជាតិ** ..... 21

III. ឧបសម្ព័ន្ធ ..... 24

**កំណត់សម្គាល់បច្ចេកទេស** ..... 26

# សេចក្ដីអធិប្បាយសង្ខេប

ស្ថានភាពសេដ្ឋកិច្ចកម្ពុជាឆ្នាំ២០១៧ រំពឹងថាអាចសម្រេចបានកំណើនប្រកបដោយផ្លែផ្កា ក្នុងនោះ អតិផរណា និង អត្រាប្ដូរប្រាក់ ប្រែប្រួលក្នុងរង្វង់ដែលអាចគ្រប់គ្រងបាន ជាមួយនិងទុនបម្រុងអន្តរជាតិ បានកំពុងកើនឡើងជាលំដាប់ដែលអាចធានាការនាំចូលទំនិញ និងសេវា បានរហូតដល់ ៦ ខែ។ ស្ថានភាពហិរញ្ញវត្ថុសាធារណៈ មានភាពប្រសើរឡើង តាមរយៈការសម្រេចបានចំណូលសរុបប្រចាំឆ្នាំ ច្រើនជាងច្បាប់ហិរញ្ញវត្ថុ ខណៈការអនុវត្តចំណាយត្រូវបានគ្រប់គ្រង និងពង្រឹងឱ្យកាន់តែមានប្រសិទ្ធភាព ពោលគឺការអនុវត្តចំណាយ មិនឱ្យលើសពីចំណាយសរុបប្រចាំឆ្នាំ ដែលបានគ្រោងក្នុងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០១៧។ ស្ថានភាពរូបិយវត្ថុទូទៅធៀប ផ.ស.ស និងកំណើនរូបិយវត្ថុទូទៅ មានអត្រាខ្ពស់នៅឆ្នាំ២០១៧ នេះ គួបផ្សំនឹងភាពប្រសើរឡើងនៃសកម្មភាពវិនិយោគឯកជនក្នុងនិងក្រៅប្រទេស, ទេសចរណ៍, សំណង់, ការនាំចូលសម្រាប់ឧស្សាហកម្មបម្រើទីផ្សារក្នុងស្រុក និងការងើបឡើងវិញនៃផ្នែកផលិតកម្មកសិកម្ម ដែលរួមមានទាំងទិន្នផល និងថ្លៃ។ យ៉ាងណាក្ដី ទំហំនាំចេញសរុប ជាពិសេសកាត់ដេរនិងស្បែកជើង បានបន្តថមថយកំណើន នៅឆ្នាំ២០១៧ នេះ។

**កសិកម្ម**

**សកម្មភាពកសិកម្មត្រីមាសទី៤ ឆ្នាំ២០១៧ មានភាពប្រសើរល្អ ស្របគ្នានឹងការបង្កើនវិនិយោគរបស់ឯកជនលើវិស័យកសិកម្ម ជាពិសេសការបន្ថែមទុនវិនិយោគលើផ្នែកកសិ-ឧស្សាហកម្ម។** ជាក់ស្ដែង ការដាំដុះស្រូវ, កៅស៊ូ និងដំណាំរួមផ្សំនិងដំណាំឧស្សាហកម្ម សម្រេចលើផ្ទៃដីប្រមាណ ៤,៣៨ លានហិកតា ដោយមានកំណើន ១,៨% ធៀបឆ្នាំមុន។ បរិមាណផលស្រូវសម្រេចបាន ៧,១៨ លានតោន ដោយមានកំណើន ២,៩% លើផ្ទៃដីប្រមូលផល ២,៣៨ លានហ.ត។ ទន្ទឹមនេះ ការនាំចេញអង្ករកម្ពុជាទៅក្រៅប្រទេស ក្នុងបរិមាណ ៥៧៣ ពាន់តោន ដោយមានកំណើន ៩,១%។ ទន្ទឹមនឹងការងើបឡើងវិញនូវថ្លៃកៅស៊ូក្នុងស្រុក និងក្រៅប្រទេស កម្ពុជាបានផលិតកៅស៊ូ ចំនួន ១៩៣ ពាន់តោន ដោយមានកំណើន ៥១,២% ក្នុងនោះ ៨១,៣% ត្រូវបាននាំចេញទៅក្រៅប្រទេស។ យោងលើកំណើនវារីវប្បកម្ម និងអំណោយផលនៃអាកាសធាតុ ផលិតផលជលផលសរុប សម្រេចបាន ៨៥៦ ពាន់តោន បានកើនឡើង ៦,៧% ធៀបឆ្នាំមុន។

**ទេសចរណ៍**

**ស្ថានភាពទេសចរណ៍ត្រីមាសទី៤ ឆ្នាំ២០១៧ បានងើបឡើងវិញគួរឱ្យកត់សម្គាល់ ពោលគឺសម្រេចបានកំណើនពីរខ្ទង់។** កម្ពុជាទទួលបានអ្នកដំណើរប្រមាណ ១,៦៩ លាននាក់ ដែលមានកំណើនលើសត្រីមាសដូចគ្នាឆ្នាំ២០១៦ ចំនួន ១២,៤%។ ក្នុងចំណោមអ្នកដំណើរ ១,៦៩ លាននាក់ ភ្ញៀវមកពីតំបន់អាស៊ីប៉ាស៊ីហ្វិកឈរលើលេខមួយដែលមានកំណើន ១៣,៣%,

តំបន់អឺរ៉ុបឈរលើលេខពីរ មានកំណើន ៧,៩% និងតំបន់អាមេរិក ថមថយកំណើនមកនៅត្រឹម ៥,៤% ខណៈភ្ញៀវមកពីតំបន់ផ្សេងៗ បានធ្លាក់ចុះកំណើន ២%។ តាមការសង្កេតកំណើនខ្ពស់នេះ គឺមានការចូលរួមជាបន្តបន្ទាប់ពីការពង្រីកជើងហោះហើរត្រង់, ការពង្រីកទីផ្សារ, ការផ្សព្វផ្សាយពីតំបន់សក្តានុពលទេសចរណ៍, ការវិនិយោគឯកជនលើសំណង់ទេសចរណ៍ និងការរក្សាបានស្ថិរភាពនយោបាយក្នុងប្រទេស។ ក្នុងន័យនេះ ការងើបឡើងវិញនូវកំណើនទេសចរណ៍ពិភពលោក ក៏ជាកត្តាសំខាន់ក្នុងការជំរុញកំណើនវិស័យទេសចរណ៍កម្ពុជា (របាយការណ៍តាមដានទេសចរណ៍ពិភពលោក UNWTO, October 2017)។

**សំណង់**

**សកម្មភាពសាងសង់ត្រីមាសទី៤ ឆ្នាំ២០១៧ បានបន្តមានភាពប្រសើរ យោងតាមកំណើនគម្រោងអនុញ្ញាតសាងសង់, ការនាំចូលគ្រឿងសំណង់, គម្រោងវិនិយោគឯកជនលើផ្នែកពាណិជ្ជកម្មនិងទេសចរណ៍ និងការផ្តល់កម្ចីសម្រាប់ផ្នែកសំណង់។** សម្រាប់ត្រីមាសទី៤ ឆ្នាំ២០១៧ សំណើអនុញ្ញាតសាងសង់ មានចំនួន ៨៩៦ គម្រោង ដែលមានក្រឡាផ្ទៃ ២,២៤ លានម៉ែត្រការ៉េ ក្នុងនោះ សំណង់លំនៅដ្ឋាននិងភូមិគ្រឹះមាន ៣៩%, ពាណិជ្ជកម្ម ៣៩,៥%, ឧស្សាហកម្ម ១៦,៧% និងសំណង់ផ្សេងៗប្រមាណ ៤,៧%។ នៅត្រីមាសទី៤ ឆ្នាំ២០១៧ នេះដែរ ការនាំចូលគ្រឿងសំណង់មានបរិមាណ ៧៥០ ពាន់តោន ដោយមានកំណើន ៣៧,៣% ធៀបឆ្នាំមុន។ ការផ្តល់កម្ចីដោយគ្រឹះស្ថានមិនបម្រើសេវាហិរញ្ញវត្ថុក្នុងជំនួញសំណង់បានថមថយកំណើនពី ៤២,១% ក្នុងត្រីមាសទី៤ ឆ្នាំ២០១៦/២០១៥ មកនៅ ២៧% ក្នុងត្រីមាសទី៤ ឆ្នាំ២០១៧/២០១៦។

**ស្ថានភាពហិរញ្ញវត្ថុសាធារណៈ**[1]

ការអនុវត្តថវិការដ្ឋនៅត្រឹមត្រីមាសទី៤ ឆ្នាំ២០១៧ មានភាពល្អប្រសើរ ដោយការប្រមូលចំណូលបានខ្ពស់ជាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ២០១៧ និងការអនុវត្តចំណាយមានល្បឿនលឿនជាងឆ្នាំកន្លងទៅ។ យោងទិន្នន័យពីអគ្គនាយកដ្ឋានរតនាគារជាតិ ចំណូលចរន្តអនុវត្តបាន ១៦.៥៣១ ប៊ីលានរៀល (១៨,៥% នៃ ផ.ស.ស) គឺខ្ពស់ជាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ២០១៧ ប្រមាណ ៦,៥% ក្នុងនោះ ចំណូលពីអគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា គឺខ្ពស់ជាងច្បាប់ហិរញ្ញវត្ថុ ១៣,៣% និង ៤,៤%។

យោងទិន្នន័យពីអគ្គនាយកដ្ឋានរតនាគារជាតិ ចំណាយចរន្តនៅត្រឹមត្រីមាសទី៤ ឆ្នាំ២០១៧ អនុវត្តបាន ១២.០៤៤ ប៊ីលានរៀល (១៣,៥% នៃ ផ.ស.ស) គឺទាបជាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ២០១៧ ប្រមាណ ៧,៧% ក្នុងនោះ ចំណាយលើផ្នែករដ្ឋបាលទូទៅ អនុវត្តបាន ៣.៣៩៨ ប៊ីលានរៀល ឬ ១៦០,៨% នៃច្បាប់ហិរញ្ញវត្ថុ។ ខណៈចំណាយ

[1] ទិន្នន័យបណ្តោះអាសន្នពីអគ្គនាយកដ្ឋានរតនាគារជាតិ

លើផ្នែកការពារនិងសន្តិសុខ ៩៣,៥%, រដ្ឋបាលសង្គមកិច្ច ៩២,៥% និងរដ្ឋបាលសេដ្ឋកិច្ច ៧៨,៩% នៃច្បាប់ហិរញ្ញវត្ថុ។ ជារួម តុល្យភាពចរន្តសាច់ប្រាក់មានអតិរេកចំនួន ៤.២៦៨ ប៊ីលានរៀល ដែលអាចរួមចំណែកផ្តល់ហិរញ្ញប្បទានដល់ការវិនិយោគ និងបង្កើនប្រាក់សន្សំ។

**អតិផរណា និង អត្រាប្តូរប្រាក់**

អតិផរណាក្នុងត្រីមាសទី៤ ឆ្នាំ២០១៧ នេះ មានអត្រាជាមធ្យម ៣% គឺមានកំណើនប្រហែលត្រីមាសទី៤ ឆ្នាំ២០១៦ ក្នុងអត្រា ២,៩%។ ស្ថិរភាពអតិផរណានៅចុងឆ្នាំនេះ ដោយសារការថមថយកំណើនចំណាយលើក្រុមអាហារ, ភេសជ្ជៈ, ថ្នាំជក់, សម្លៀកបំពាក់, គ្រឿងសង្ហារឹមនិងសុខាភិបាល។ យ៉ាងណាក្តី ចំណាយលើការដឹកជញ្ជូន មានការកើនឡើងខ្ពស់ពីអត្រា -៧,៤% ទៅ ៣,៥% ស្របនឹងការងើបឡើងវិញនៃថ្លៃប្រេងឥន្ធនៈ រវាងត្រីមាសទី៤ ឆ្នាំ២០១៦ និងឆ្នាំ២០១៧។ សម្រាប់ត្រីមាសទី៤ ឆ្នាំ២០១៧ នេះដែរ អត្រាប្តូរប្រាក់ជាមធ្យម ៤.០៣៧ រៀល/ដុល្លារអាមេរិក មានការប្រែប្រួលត្រឹម -០,១១% ប៉ុណ្ណោះ។ **ទន្ទឹមនឹងការរក្សាបានស្ថេរភាពអត្រាប្តូរប្រាក់ ទុនបម្រុងជារូបិយប័ណ្ណបរទេស មានកម្រិតប្រមាណ ៣៨,២% នៃ ផ.ស.ស ឆ្នាំ២០១៧ (ប៉ាន់ស្មាន) ដែលអាចធានាការនាំចូលទំនិញនិងសេវាបានប្រមាណ ៦ខែ។**

**ប្រតិបត្តិការរូបិយវត្ថុ និងឥណទាន**

**ការផ្គត់ផ្គង់រូបិយវត្ថុក្នុងសេដ្ឋកិច្ចកម្ពុជា គិតត្រឹមត្រីមាសទី៤ ឆ្នាំ២០១៧ រក្សាបានស្ថេរភាពល្អប្រសើរ ស្របគ្នានឹងការរីតបន្តឹងឥណទានដែលមិនបម្រើសេវាហិរញ្ញវត្ថុ និងឥណទានដែលជាតម្រូវការផ្ទាល់ខ្លួន។** ការផ្គត់ផ្គង់រូបិយវត្ថុ មានកំណើនសមស្របក្នុងអត្រា ២៣,៨% ខណៈឥណទានផ្នែកធនាគារមានកំណើនក្នុងអត្រា ១៨,៥%។ ឥណទានផ្តល់ទៅគ្រឹះស្ថានមិនមែនហិរញ្ញវត្ថុ បានបន្ថយល្បឿនពី ១៧,៥% ក្នុងត្រីមាសទី៤ ឆ្នាំ២០១៦ មកនៅ ១៤,៨% ក្នុងត្រីមាសទី៤ ឆ្នាំ២០១៧ ក្នុងនោះ ល្បឿនកំណើនឥណទានបានថមថយលើផ្នែកកសិកម្ម, សំណង់ និងការជួញដូររាយ។ **ប៉ុន្តែការជួញដូរអចលនទ្រព្យ និងកម្ចីទិញផ្ទះជាកម្មសិទ្ធិផ្ទាល់ខ្លួន មានកំណើនដល់ ៤០,២% និង ៩១,២% រៀងគ្នា គិតត្រឹមត្រីមាសទី៤ ឆ្នាំ២០១៧។**

**ពាណិជ្ជកម្មក្រៅប្រទេស**

**ពាណិជ្ជកម្មទំនិញ នៅត្រីមាសទី៤ ឆ្នាំ២០១៧ មានសកម្មភាពល្អប្រសើរពោលគឺ មានតម្រូវការខ្ពស់គួរឱ្យកត់សម្គាល់លើមុខទំនិញនាំចូលសម្រាប់បម្រើផលិតកម្មក្នុងស្រុកនិងការនាំចេញ និងការនាំចេញមុខទំនិញសំខាន់ៗ បានបន្តមានកំណើនខ្ពស់។** ការនាំចូលមុខទំនិញគ្រប់មុខនៅត្រីមាសទី៤ ឆ្នាំ២០១៧ មានទំហំ ១៣.៨២១ ប៊ីលានរៀល ដោយមានកំណើន ១០,៧% ធៀបឆ្នាំមុន ក្នុងនោះ វាយនភ័ណ្ឌនិងសម្លៀកបំពាក់ ដែលមានសមាមាត្រ ២៧,៥% នៃទំហំទឹកប្រាក់នាំចូលសរុប មានកំណើន ៣,៩%។ **តាមការសង្កេត កំណើនខ្ពស់លើបរិមាណនាំចូលបារី ភេសជ្ជៈ និងគ្រឿងស្រវឹងមានចំនួន ៧២,៩%, បរិក្ខារសំណង់ ៣៧,៣%,**

**ទោចក្រយានយន្ត ២៣%, គ្រឿងបន្លាស់យានយន្ត ៧៥,៣% និងបរិក្ខារត្រជាក់ (ម៉ាស៊ីនត្រជាក់ និងឧបករណ៍ត្រជាក់ផ្សេងៗ) ៥០,៣% ធៀបឆ្នាំមុន។**

ចំពោះសកម្មភាពពាណិជ្ជកម្មក្រៅប្រទេស ការនាំចេញសរុបរបស់កម្ពុជា នៅត្រីមាសទី៤ ឆ្នាំ២០១៧ មានទំហំ ១១.៦៣១ ប៊ីលានរៀល មានកំណើន ១៧,៣% ធៀបឆ្នាំមុន ក្នុងនោះ ផលិតផលកាត់ដេរនិងស្បែកជើង មានកំណើន ១៣,៧% និងផលិតផលកសិកម្ម ៣៨,៥%។

ការនាំចេញទំនិញទៅទីផ្សារអាមេរិក មានស្ថានភាពប្រសើរដោយមានកំណើន ២៥,៦% លើផលិតផលកាត់ដេរនិងស្បែកជើង។ ការនាំចេញទៅទីផ្សារអឺរ៉ុប, អាស៊ាន និងជប៉ុន បានងើបឡើងវិញនៅត្រីមាសទី៤ ដោយមានកំណើន ១៥,២%, ១៧,១% និង ៣០,៤% រៀងគ្នា។

### ការវិនិយោគឯកជន

**ជារួមស្ថានភាពវិនិយោគឯកជននៅកម្ពុជា ឆ្នាំ២០១៧ (គម្រោងថ្មី) ទទួលបានលទ្ធផលជាផ្លែផ្កា និងមានកំណើនខ្ពស់ធៀបឆ្នាំ២០១៦ ពោលគឺ មានទុនវិនិយោគប្រមាណ ៥.២១៧ លានដុល្លារអាមេរិក[2] ទោះបីជាសំណើសុំវិនិយោគ ក្នុងត្រីមាសទី៤ ឆ្នាំ២០១៧ បានធ្លាក់ចុះយ៉ាងណាក្តី។** យោងតាមទិន្នន័យនេះ គម្រោងវិនិយោគថ្មីភាគច្រើន គឺផ្តោតលើផ្នែកហេដ្ឋារចនាសម្ព័ន្ធ ដើម្បីគាំទ្រសេវាកម្ម (ព្រលានយន្តហោះ និងបណ្តាញទូរគមនាគមន៍) និងផ្នែកទេសចរណ៍ (មជ្ឈមណ្ឌលពាណិជ្ជកម្ម និងសណ្ឋាគារផ្កាយ៥)។ ដោយឡែក ការធ្លាក់ចុះនៃគម្រោងវិនិយោគថ្មីក្នុងផ្នែកកសិកម្ម និងកសិ-ឧស្សាហកម្ម ដោយសារការបញ្ឈប់ការផ្តល់សម្បទានដីសេដ្ឋកិច្ចតទៅទៀត។

ឲ្យឲ្យ✲ಖಖ

---

[2] ទិន្នន័យវិនិយោគឯកជន ផ្តោតលើគម្រោងថ្មីក្រៅតំបន់សេដ្ឋកិច្ចពិសេសប៉ុណ្ណោះ។

# ស្ថិតិសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ១. សូចនាករសេដ្ឋកិច្ចសំខាន់ៗ

*តារាង 1 ÷ ទិន្នន័យសេដ្ឋកិច្ចសំខាន់ៗ*

| | ឯកតា | ត្រីមាសទី៤ | | |
|---|---|---|---|---|
| | | ២០១៥ | ២០១៦ | ២០១៧ |
| **សូចនាករម៉ូលដ្ឋាន** | | | | |
| អតិផរណា (កំណើនប្រចាំឆ្នាំ) | % | 2.8 | 3.9 | 2.2 |
| អតិផរណា (កំណើនមធ្យមប្រចាំឆ្នាំ) | % | 1.1 | 2.9 | 3.0 |
| អត្រាប្តូរប្រាក់រៀល/ដុល្លារ (មធ្យមប្រចាំឆ្នាំ) | រៀល | 4,051 | 4,042 | 4,037 |
| **ហិរញ្ញវត្ថុសាធារណៈ** | | | | |
| ចំណូលចរន្ត | ប៊ីលានរៀល | 4,117 | 3,452 | 4,285 |
| ចំណាយចរន្ត | ប៊ីលានរៀល | 3,471 | 4,226 | 3,806 |
| តុល្យភាពថវិកាចរន្ត | ប៊ីលានរៀល | 646 | (774) | 479 |
| **ឥណទាន និងរូបិយវត្ថុ** | | | | |
| រូបិយវត្ថុទូទៅ (% នៃ ផសស) | % | 66.5 | 71.5 | 79.1 |
| កំណើនរូបិយវត្ថុទូទៅ | % | 14.7 | 18.0 | 24.3 |
| ប្រាក់បញ្ញើជារូបិយប័ណ្ណ (% នៃរូបិយវត្ថុទូទៅ) | % | 83.0 | 83.2 | 83.3 |
| **ពាណិជ្ជកម្មអន្តរជាតិ** | | | | |
| ទំនិញនាំចេញ | ប៊ីលានរៀល | 9,357 | 9,915 | 11,631 |
| ទំនិញនាំចូល | ប៊ីលានរៀល | 11,970 | 12,488 | 13,821 |
| តុល្យភាពពាណិជ្ជកម្ម | ប៊ីលានរៀល | (2,614) | (2,573) | (2,190) |
| **វិនិយោគឯកជន** | | | | |
| គម្រោង | ចំនួន | 31 | 28 | 25 |
| អចលនទ្រព្យ | លានដុល្លារ | 512 | 507 | 120 |
| បង្កើតការងារ | ពាន់នាក់ | 29,069 | 26,692 | 21,220 |
| **ទេសចរណ៍** | | | | |
| អ្នកធ្វើដំណើរឆ្លងកាត់ប្រទេសកម្ពុជា | ពាន់នាក់ | 1,428 | 1,503 | 1,689 |
| ក្នុងនោះ អ្នកទេសចរ | ពាន់នាក់ | 1,281 | 1,344 | 1,543 |

| | ឯកតា | ត្រីមាសទី៤ | | |
|---|---|---|---|---|
| | | ២០១៥ | ២០១៦ | ២០១៧ |
| **វិស័យសំណង់** | | | | |
| គម្រោង | ចំនួន | 565 | 627 | 896 |
| ក្រឡាផ្ទៃ | ម២ | 3,186,700 | 2,350,818 | 2,238,338 |
| តម្លៃសាងសង់ | លានដុល្លារ | 1,587 | 974 | 1,163 |
| **ថ្លៃទំនិញលើទីផ្សារអន្តរជាតិ (គិតជាដុល្លារអាមេរិក)** [3] | | | | |
| អង្ករ | ដុល្លារ/ តោន | 363 | 373 | 389 |
| ប្រេងឆៅ (Brent) -- បារ៉ែល | ដុល្លារ/ បារ៉ែល | 38 | 54 | 64 |
| កៅស៊ូ | ដុល្លារ/ តោន | 1,248 | 1,930 | 1,652 |
| មាស | ដុល្លារ/ អោន | 974 | 1,157 | 1,387 |

ប្រភព: ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, វិទ្យាស្ថានជាតិស្ថិតិ, និងធនាគារជាតិ

[3] គឺជាថ្លៃទំនិញចុងត្រីមាស

# ២. សូចនាករតាមវិស័យ

## ២.១. សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់

*តារាង 2 ÷ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (មធ្យមប្រចាំត្រីមាសទី៤) -- ឆ្នាំ២០១៧*

| សូចនាករ | ត្រីមាសទី៤ | | |
|---|---|---|---|
| | ២០១៥ | ២០១៦ | ២០១៧ |
| **មុខទំនិញគ្រប់មុខ** | 159.9 | 164.6 | 169.6 |
| អាហារនិងភេសជ្ជៈមិនមែនជាតិស្រវឹង | 188.6 | 199.0 | 206.4 |
| ភេសជ្ជៈមានជាតិស្រវឹង និង ថ្នាំជក់ | 141.7 | 156.0 | 159.7 |
| សម្លៀកបំពាក់ និង ស្បែកជើង | 134.2 | 140.2 | 144.4 |
| ផ្ទះសំបែង ទឹក អគ្គិសនី ឧស្ម័ន និងឥន្ធនៈដទៃទៀត | 126.6 | 124.4 | 124.4 |
| គ្រឿងសង្ហារឹម សម្ភារប្រើប្រាស់ និងការថែទាំ | 143.5 | 147.9 | 150.1 |
| សុខាភិបាល | 127.9 | 131.2 | 133.2 |
| ការដឹកជញ្ជូន | 117.7 | 108.9 | 112.8 |
| គមនាគមន៍ | 67.9 | 68.3 | 68.1 |
| ការកំសាន្ត និងវប្បធម៌ | 113.5 | 117.3 | 118.8 |
| ការសិក្សា | 159.3 | 160.1 | 159.9 |
| ភោជនីយដ្ឋាន | 229.4 | 239.6 | 253.2 |
| ទំនិញ និង សេវាកម្មផ្សេងៗ | 138.9 | 139.0 | 140.6 |

ប្រភព: វិទ្យាស្ថានជាតិស្ថិតិ, ក្រសួងផែនការ

*រូបភាព 1 ÷ ស្ថានភាពអតិផរណា (មធ្យមប្រចាំត្រីមាស)*




ប្រភព: វិទ្យាស្ថានជាតិស្ថិតិ, ក្រសួងផែនការ

## ២.៣. អត្រាប្តូរប្រាក់

*តារាង 3 ÷ អត្រាប្តូរប្រាក់រៀលធៀបដុល្លារអាមេរិក (មធ្យមប្រចាំត្រីមាស) -- ឆ្នាំ២០១៧*

| អត្រាប្តូរប្រាក់ចុងខែ | ត្រីមាសទី១ | ត្រីមាសទី២ | ត្រីមាសទី៣ | ត្រីមាសទី៤ |
|---|---|---|---|---|
| 2011 | 4,043 | 4,045 | 4,095 | 4,065 |
| 2012 | 4,030 | 4,038 | 4,056 | 4,007 |
| 2013 | 3,995 | 4,032 | 4,062 | 4,020 |
| 2014 | 3,994 | 4,026 | 4,060 | 4,070 |
| 2015 | 4,043 | 4,056 | 4,092 | 4,051 |
| 2016 | 4,023 | 4,055 | 4,094 | 4,042 |
| 2017 | 4,016 | 4,047 | 4,080 | 4,037 |

ប្រភព: ធនាគារជាតិនៃកម្ពុជា

*រូបភាព 2 ÷ ស្ថានភាពអត្រាប្តូរប្រាក់រៀលធៀបដុល្លារអាមេរិក (មធ្យមប្រចាំត្រីមាស) -- ឆ្នាំ២០១៧*




ប្រភព: ធនាគារជាតិនៃកម្ពុជា

## ២.៤. ហិរញ្ញវត្ថុសាធារណៈ

*តារាង 4 ÷ តារាងប្រតិបត្តិការហិរញ្ញវត្ថុរដ្ឋ (TOFE) -- ផ្នែកចំណូល*

| លានរៀល | ត្រីមាសទី៤ | | |
|---|---|---|---|
| | ២០១៥ | ២០១៦ | ២០១៧ |
| I. ចំណូលក្នុងប្រទេស | 4,209,965 | 3,502,061 | 4,321,720 |
| ១. ចំណូលចរន្ត | 4,158,476 | 3,452,272 | 4,284,598 |
| *ក. ចំណូលសារពើពន្ធ* | 2,791,118 | 2,722,085 | 3,499,989 |
| ១. ពន្ធផ្ទាល់ | 481,739 | 495,591 | 622,232 |
| ពន្ធលើប្រាក់បៀវត្ស | 119,455 | 124,289 | 164,567 |
| ពន្ធលើប្រាក់ចំណេញ | 317,084 | 316,574 | 392,281 |
| ពន្ធលើផលទុនដីធ្លី និងផ្ទះសំបែង | 45,200 | 54,728 | 65,384 |
| ២. ពន្ធប្រយោល | 1,701,483 | 1,742,078 | 2,306,020 |
| ពន្ធលើផលរបរ | 7,233 | 47 | 5 |
| អាករលើតម្លៃបន្ថែម | 980,432 | 1,051,422 | 1,193,878 |
| អាករពិសេស | 648,719 | 667,766 | 1,065,609 |
| ចំណូលពន្ធផ្សេងៗទៀត | 65,099 | 22,842 | 46,527 |
| ៣. ពន្ធពាណិជ្ជកម្មក្រៅប្រទេស | 607,897 | 484,417 | 571,737 |
| ពន្ធនាំចូល | 494,160 | 475,669 | 557,009 |
| ពន្ធនាំចេញ | 69,792 | 8,683 | 14,573 |
| ពន្ធនាំចេញផ្សេងៗទៀត | 43,944 | 65 | 155 |
| *ខ. ចំណូលមិនមែនសារពើពន្ធ* | 1,367,358 | 730,186 | 784,608 |
| ចំណូលពីទេសចរណ៍ | 689 | 461 | 177 |
| ចំណូលពីព្រៃឈើ | 5,379 | 5,225 | 8,662 |
| ចំណូលពីការជួលសហគ្រាស | 321 | 1,700 | 836 |
| ចំណូលពីអាកាសចរស៊ីវិល | 49,873 | 43,302 | 34,311 |
| ចំណូលពីសម្បទាន | 46,936 | 86,318 | 122,269 |
| ចំណូលពីប្រៃសណីយ៍ និងទូរគមនាគមន៍ | 68,766 | 85,526 | 74,148 |
| អាករស្ថានទូត (ចំណូលពីលិខិតឆ្លងដែន និង ទិដ្ឋាការ) | 107,911 | 139,421 | 170,486 |
| ផលពីការបង់សិទ្ធិប្រលង | 79,278 | 74,723 | 42,991 |
| ចំណូលពីការជួល | 4,524 | 5,413 | 4,447 |
| ចំណូលមិនមែនពន្ធផ្សេងៗ | 1,003,683 | 288,099 | 326,283 |
| ២. ចំណូលមូលធន | 51,488 | 49,789 | 37,123 |
| ការប្រមូលមកវិញនៃឥណទាន | 51,488 | 49,789 | 37,123 |

ប្រភព: អគ្គនាយកដ្ឋានគោលនយោបាយ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## *តារាង 5 ÷ តារាងប្រតិបត្តិការហិរញ្ញវត្ថុរដ្ឋ (TOFE) -- ផ្នែកចំណាយ*

| លានរៀល | ត្រីមាសទី៤ | | |
|---|---|---|---|
| | ២០១៥ | ២០១៦ | ២០១៧ |
| **II. ចំណាយសរុប** | 4,446,278 | 5,700,137 | 5,128,725 |
| **១. ចំណាយចរន្ត** | 3,037,982 | 4,225,930 | 3,806,008 |
| *ក. ការពារ និងសន្តិសុខជាតិ* | 427,059 | 891,644 | 845,785 |
| *ខ. រដ្ឋបាលស៊ីវិល* | 2,586,811 | 3,284,841 | 2,925,131 |
| *គ. ចំណាយការប្រាក់* | 24,112 | 49,445 | 35,093 |
| **២. ចំណាយមូលធន** | 1,408,296 | 1,474,207 | 1,322,717 |
| ហិរញ្ញប្បទានក្នុងស្រុក | 632,345 | 728,595 | 804,238 |
| ពីចំណូលក្នុងស្រុក | 609,966 | 441,660 | 804,238 |
| ពីជំនួយជាទំនិញ | 22,378 | 286,935 | 0 |
| ហិរញ្ញប្បទានពីបរទេស | 775,951 | 745,612 | 518,480 |
| កែតម្រូវ | (46,326) | (42,860) | 0 |
| ***និនភាពចរន្ត (សាច់ប្រាក់)*** | 1,074,168 | (816,518) | 478,590 |
| ***និនភាពទូទៅ (សាច់ប្រាក់)*** | (282,640) | (2,240,936) | (807,005) |

ប្រភពៈ អគ្គនាយកដ្ឋានគោលនយោបាយ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## *តារាង 6 ÷ តារាងប្រតិបត្តិការហិរញ្ញវត្ថុរដ្ឋ (TOFE) -- ផ្នែកហិរញ្ញប្បទាន*

| លានរៀល | ត្រីមាសទី៤ | | |
|---|---|---|---|
| | ២០១៥ | ២០១៦ | ២០១៧ |
| **III. ហិរញ្ញប្បទាន** | 1,625,354 | 2,240,936 | 807,005 |
| **១. ហិរញ្ញប្បទានពីបរទេស** | 739,742 | 873,624 | 429,908 |
| ទ្រទ្រង់ថវិកា | 22,378 | 286,935 | 0 |
| ជំនួយគម្រោងអភិវឌ្ឍន៍ | 787,616 | 712,163 | 518,237 |
| រំលោះបំណុលបរទេស | (70,253) | (125,474) | (88,329) |
| **២. ហិរញ្ញប្បទានក្នុងស្រុក** | (198,781) | (247,538) | 3,817 |
| បញ្ញើរដ្ឋាភិបាល | (8,172,299) | (232,805) | 12,734 |
| វិស័យឯកជន | 232,165 | (29,377) | 0 |
| ផ្សេងៗ | 7,741,353 | 14,644 | (8,917) |
| **៣. ប្រតិបត្តិការកំពុងដំណើរការ** | 1,084,394 | 1,614,850 | 373,280 |

ប្រភពៈ អគ្គនាយកដ្ឋានគោលនយោបាយ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## តារាង 7៖ ចំណាយចរន្តតាមក្រសួង

| លានរៀល | ត្រីមាសទី៤ | | |
|---|---|---|---|
| | ២០១៥ | ២០១៦ | ២០១៧ |
| **សរុបចំណាយជាប្រចាំ** | 3,471,382 | 4,225,930 | 3,806,008 |
| **១.រដ្ឋបាលទូទៅ** | 885,472 | 1,158,992 | 1,081,476 |
| ព្រះបរមរាជវាំង | 24,998 | 25,612 | 17,849 |
| រដ្ឋសភា | 24,209 | 1,009 | 33,325 |
| ព្រឹទ្ធសភា | 16,536 | 16,739 | 18,331 |
| ក្រុមប្រឹក្សាធម្មនុញ្ញ | 1,595 | 1,645 | 2,251 |
| ទីស្តីការគណៈរដ្ឋមន្ត្រី | 171,497 | 303,027 | 153,998 |
| ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | 5,564 | 6,819 | 3,993 |
| ក្រសួងមហាផ្ទៃ-រដ្ឋបាលទូទៅ | 47,456 | 52,077 | 31,575 |
| ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច | 9,015 | 9,876 | 11,509 |
| ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | 16,985 | 27,994 | 30,692 |
| ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | 464,560 | 522,508 | 644,207 |
| ក្រសួងផែនការ | 17,057 | 19,497 | 26,544 |
| ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | 52,280 | 60,465 | 47,062 |
| គ.ជ.ប | 7,612 | 79,002 | 31,959 |
| អាជ្ញាធរសវនកម្មជាតិ | 4,075 | 4,097 | 3,207 |
| អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងអំពើពុករលួយ | 6,747 | 11,616 | 8,751 |
| ក្រសួងមុខងារសាធារណៈ | 15,287 | 17,010 | 16,221 |
| **២.ការពារ និងសន្តិសុខ** | 650,235 | 937,778 | 888,533 |
| ក្រសួងការពារជាតិ | 312,243 | 516,661 | 528,851 |
| ក្រសួងមហាផ្ទៃ-សន្តិសុខសាធារណៈ | 303,550 | 374,982 | 316,934 |
| ក្រសួងយុត្តិធម៌ | 34,442 | 46,134 | 42,748 |
| **៣.រដ្ឋបាលសង្គមកិច្ច** | 1,379,525 | 1,498,491 | 1,393,682 |
| ក្រសួងព័ត៌មាន | 17,503 | 22,059 | 17,967 |
| ក្រសួងសុខាភិបាល | 474,861 | 486,990 | 396,931 |
| ក្រសួងអប់រំ យុវជន និងកីឡា | 598,037 | 606,717 | 629,845 |
| ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | 20,900 | 31,692 | 24,465 |
| ក្រសួងបរិស្ថាន | 19,912 | 23,741 | 24,235 |
| ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | 148,528 | 193,349 | 198,390 |
| ក្រសួងធម្មការ និងកិច្ចការសាសនា | 12,078 | 14,116 | 16,339 |
| ក្រសួងកិច្ចការនារី | 14,829 | 12,928 | 12,872 |
| ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | 72,878 | 106,898 | 72,638 |

| លានរៀល | ត្រីមាសទី៤ | | |
|---|---|---|---|
| | ២០១៥ | ២០១៦ | ២០១៧ |
| **៤.រដ្ឋបាលសេដ្ឋកិច្ច** | 492,482 | 625,073 | 419,317 |
| រដ្ឋ. ដ្ឋានអាកាសចរណ៍ស៊ីវិល | 43,254 | 37,898 | 21,293 |
| ក្រសួងរ៉ែ និងថាមពល | 10,470 | 16,295 | 11,085 |
| ក្រសួងពាណិជ្ជកម្ម | 72,809 | 79,199 | 33,310 |
| ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | 81,938 | 89,180 | 72,155 |
| ក្រសួងអភិវឌ្ឍន៍ជនបទ | 81,927 | 89,616 | 39,101 |
| ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | 20,407 | 33,548 | 25,110 |
| ក្រសួងសាធារណៈការ និងដឹកជញ្ជូន | 108,466 | 173,705 | 141,820 |
| ក្រសួងទេសចរណ៍ | 11,080 | 29,742 | 17,948 |
| ក្រសួងធនធានទឹក និងឧតុនិយម | 48,405 | 57,678 | 43,539 |
| ក្រសួងឧស្សាហកម្ម និងសិប្បកម្ម | 13,727 | 18,212 | 13,956 |
| **ចំណាយផ្សេងៗ** | 63,668 | 5,597 | 23,000 |

ប្រភព: អគ្គនាយកដ្ឋានគោលនយោបាយ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

*រូបភាព 3 ÷ ស្ថានភាពតុល្យភាពថវិកាចរន្ត (គិតជាលានរៀល)*




ប្រភព: អគ្គនាយកដ្ឋានគោលនយោបាយ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ២.៥. ឥណទាន និងរូបិយវត្ថុ

*តារាង 8 ÷ ស្ថានភាពរូបិយវត្ថុ*

| (ប៊ីលានរៀល) | ត្រីមាសទី៤ | | |
|---|---|---|---|
| | ២០១៥ | ២០១៦ | ២០១៧ |
| **ទ្រព្យសកម្មបរទេសសុទ្ធ** | 26,666 | 31,687 | 42,673 |
| ទ្រព្យសកម្មបរទេស | 39,314 | 47,139 | 60,695 |
| ទ្រព្យអកម្មបរទេស | (12,648) | (15,453) | (18,022) |
| **ទ្រព្យសកម្មក្នុងស្រុកសុទ្ធ** | 22,158 | 25,288 | 28,141 |
| ឥណទានក្នុងស្រុក | 39,642 | 47,125 | 54,780 |
| ឥណទេយ្យសុទ្ធរាជរដ្ឋាភិបាល | (6,429) | (8,009) | (10,411) |
| ផ្នែកមិនមែនរដ្ឋាភិបាល | 46,071 | 55,134 | 65,191 |
| **ទ្រព្យសកម្មផ្នែកផ្សេងៗ** | (17,485) | (21,837) | (26,639) |
| ប្រាក់បញ្ញើហាមឃាត់ | (1,021) | (1,263) | (1,546) |
| មូលធន និង ធនបំរុង | (15,378) | (17,743) | (22,190) |
| ផ្សេងៗ | (1,086) | (2,831) | (2,903) |
| **រូបិយវត្ថុទូទៅ (M2)** | 48,823 | 56,974 | 70,814 |
| រូបិយវត្ថុ (M1) | 6,741 | 7,135 | 9,171 |
| *រូបិយវត្ថុក្រៅធនាគារ* | 5,897 | 6,357 | 8,072 |
| *ប្រាក់បញ្ញើចរន្ត* | 845 | 778 | 1,099 |
| រូបិយវត្ថុផ្សេងៗ | 42,082 | 49,839 | 61,644 |
| *ប្រាក់បញ្ញើមានកាលកំណត់ និងសន្សំ* | 1,550 | 2,321 | 2,644 |
| *ប្រាក់បញ្ញើជារូបិយប័ណ្ណ (បរទេស)* | 40,532 | 47,519 | 59,000 |

ប្រភពៈ ធនាគារជាតិនៃកម្ពុជា

## ២.៦. វិស័យពាណិជ្ជកម្ម

*តារាង 9 ÷ ការនាំចូលតាមមុខទំនិញសំខាន់ៗ (គិតជាបរិមាណ)*

| មុខទំនិញ | ឯកត្តា | ត្រីមាសទី៤ | | |
|---|---|---|---|---|
| | | ២០១៥ | ២០១៦ | ២០១៧ |
| ថ្នាំពេទ្យ | ពាន់តោន | 5 | 6 | 5 |
| ភេសជ្ជៈ គ្រឿងស្រវឹង និងបារី | ពាន់កាតុង | 8,739 | 7,790 | 13,467 |
| ស្ករស និងប៊ីចេង | ពាន់តោន | 17 | 44 | 25 |
| ប្រេងឆា និងអាហារផ្សេងៗ | ពាន់កាតុង | 87 | 69 | 71 |
| បរិក្ខារសំណង់ | ពាន់តោន | 577 | 546 | 750 |
| អេឡិចត្រូនិច | ពាន់គ្រឿង | 93 | 69 | 70 |
| វាយនភ័ណ្ឌ និងសម្លៀកបំពាក់ | ពាន់តោន | 144 | 161 | 170 |
| ទោចក្រ- យានយន្ត | ពាន់គ្រឿង | 146 | 135 | 165 |
| គ្រឿងបម្លាស់យានយន្ត | ពាន់តោន | 3 | 1 | 2 |
| បរិក្ខារត្រជាក់ | ពាន់គ្រឿង | 30 | 29 | 43 |
| មាស | គីឡូក្រាម | 4 | 0 | 0 |
| ប្រេងឥន្ធនៈ | ពាន់តោន | 475 | 544 | 586 |
| ជីកសិកម្ម | ពាន់តោន | 169 | 258 | 260 |
| ផ្សេងៗ | ពាន់តោន | 3,611 | 574 | 1,220 |

ប្រភព: ទិន្នន័យពាណិជ្ជកម្មអន្តរជាតិឆ្លងតាមមាត់ច្រកគយពី អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

*រូបភាព 4 ÷ ការនាំចូលប្រេងឥន្ធនៈ បរិក្ខារសំណង់ និងវាយនភ័ណ្ឌនិងសម្លៀកបំពាក់ (ពាន់តោន និងកំណើន %)*




ប្រភព: ទិន្នន័យពាណិជ្ជកម្មអន្តរជាតិឆ្លងតាមមាត់ច្រកគយពី អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## តារាង 10 ÷ ការនាំចូលតាមមុខទំនិញសំខាន់ៗ (គិតជាប៊ីលានរៀល)

| មុខទំនិញ | ត្រីមាសទី៤ | | |
|---|---|---|---|
| | ២០១៥ | ២០១៦ | ២០១៧ |
| ថ្នាំពេទ្យ | 120 | 142 | 175 |
| ភេសជ្ជៈ គ្រឿងស្រវឹង និងបារី | 429 | 376 | 476 |
| ស្ករស និងប៊ីចេង | 25 | 56 | 41 |
| ប្រេងឆា និងអាហារផ្សេងៗ | 208 | 257 | 321 |
| សម្ភារសំណង់ | 436 | 541 | 612 |
| អេឡិចត្រូនិច | 10 | 6 | 8 |
| វាយនភ័ណ្ឌ | 3,327 | 3,660 | 3,801 |
| ទោចក្រ-យានយន្ត | 1,229 | 908 | 1,314 |
| គ្រឿងបន្លាស់យានយន្ត | 19 | 11 | 17 |
| បរិក្ខារត្រជាក់ | 52 | 77 | 69 |
| មាស | 531 | 707 | 346 |
| ប្រេងឥន្ធនៈ | 1,164 | 1,298 | 871 |
| ជីកសិកម្ម | 265 | 314 | 347 |
| ផ្សេងៗ | 4,155 | 4,135 | 5,424 |
| **សរុប** | 11,970 | 12,488 | 13,821 |

ប្រភពៈ ទំនិញពាណិជ្ជកម្មអន្តរជាតិឆ្លងតាមមាត់ច្រកគយពី អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## តារាង 11 ÷ ការនាំចេញមុខទំនិញសំខាន់ៗ (គិតជាបរិមាណ)

| មុខទំនិញ | ឯកត្តា | ត្រីមាសទី៤ | | |
|---|---|---|---|---|
| | | ២០១៥ | ២០១៦ | ២០១៧ |
| សម្លៀកបំពាក់ | ពាន់ឡូ | 38,529 | 45,499 | 48,189 |
| ស្បែកជើង | ពាន់គូ | 24,712 | 29,248 | 34,154 |
| វាយនភ័ណ្ឌផ្សេងៗ | ពាន់ឡូ | 1,838 | 1,920 | 2,723 |
| គ្រឿងបង្គុំអេឡិចត្រូនិច | ពាន់តោន | 0 | 0 | 3 |
| គ្រឿងបង្គុំរថយន្ត | ពាន់តោន | 0 | 0 | 0 |
| កង់ | ពាន់គ្រឿង | 0 | 0 | 501 |
| ឈើមូល | ពាន់ម៣ | 5 | 0 | 5 |
| ឈើកែច្នៃ | ពាន់ម៣ | 0 | 0 | 0 |
| ក្តាបន្ទះ | ពាន់តោន | 0 | 0 | 0 |
| ផលិតផលផ្សេងៗពីឈើ | ពាន់តោន | 12 | 18 | 41 |

| មុខទំនិញ | ឯកត្តា | ត្រីមាសទី៤ | | |
|---|---|---|---|---|
| | | ២០១៥ | ២០១៦ | ២០១៧ |
| អង្ករ | ពាន់តោន | 151 | 173 | 189 |
| ស្រូវ | ពាន់តោន | 0 | 0 | 0 |
| កៅស៊ូ | ពាន់តោន | 36 | 39 | 48 |
| ស្ករស | ពាន់តោន | 0 | 0 | 18 |
| ផលិតផលជលផល | ពាន់តោន | 0 | 0 | 0 |
| ផលិតផលកសិកម្មផ្សេងៗ | ពាន់តោន | 13 | 4 | 26 |
| បារី | ពាន់តោន | 1 | 1 | 1 |
| មាស | គីឡូក្រាម | 60 | 17 | 0 |
| ផលិតផលផ្សេងៗ | ពាន់តោន | 158 | 196 | 287 |

ប្រភព: ទំនិញពាណិជ្ជកម្មអន្តរជាតិឆ្លងតាមមាត់ច្រកគយពី អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

*រូបភាព 5 ÷ ស្ថានភាពមុខទំនិញនាំចេញសំខាន់ៗ (គិតជាប៊ីលានរៀល)*




ប្រភព: ទំនិញពាណិជ្ជកម្មអន្តរជាតិឆ្លងតាមមាត់ច្រកគយពី អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## រូបភាព 6 ÷ ស្ថានភាពនាំចេញទៅទីផ្សារអន្តរជាតិ (គិតជាលានដុល្លារអាមេរិក)




ប្រភព៖ ទំនិញពាណិជ្ជកម្មអន្តរជាតិឆ្លងតាមមាត់ច្រកគយពី អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## តារាង 12 ÷ មុខទំនិញនាំចេញ (គិតជាប៊ីលានរៀល)

| មុខទំនិញ | ត្រីមាសទី៤ | | |
|---|---|---|---|
| | ២០១៥ | ២០១៦ | ២០១៧ |
| សម្លៀកបំពាក់ | 5,911 | 6,137 | 6,965 |
| ស្បែកជើង | 729 | 862 | 963 |
| វាយនភ័ណ្ឌផ្សេងៗ | 172 | 104 | 145 |
| គ្រឿងបង្គុំអេឡិចត្រូនិច | 0 | 0 | 391 |
| គ្រឿងបង្គុំរថយន្ត | 0 | 0 | 7 |
| កង់ | 0 | 0 | 423 |
| ឈើមូល | 28 | 0 | 15 |
| ឈើកែច្នៃ | 0 | 0 | 0 |
| ក្តាបន្ទះ | 0 | 0 | 0 |
| ផលិតផលផ្សេងៗពីឈើ | 34 | 68 | 132 |
| អង្ករ | 400 | 404 | 495 |
| ស្រូវ | 0 | 0 | 0 |
| កៅស៊ូ | 165 | 241 | 284 |
| ស្ករស | 0 | 0 | 32 |
| ផលិតផលជលផល | 0 | 1 | 1 |
| ផលិតផលកសិកម្មផ្សេងៗ | 20 | 7 | 38 |
| បារី | 19 | 20 | 21 |
| មាស | 9 | 3 | 0 |
| ផលិតផលផ្សេងៗ | 1,870 | 2,069 | 1,719 |
| **នាំចេញសរុប** | 9,357 | 9,915 | 11,631 |

ប្រភព៖ ទំនិញពាណិជ្ជកម្មអន្តរជាតិឆ្លងតាមមាត់ច្រកគយពី អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ២.៧. ការវិនិយោគឯកជន

*តារាង 13 ÷ ស្ថិតិវិនិយោគវិស័យឯកជន (អនុម័តដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា)*

| ការអនុញ្ញាតវិនិយោគដោយ (CDC) | ឯកតា | ត្រីមាសទី៤ | | |
|---|---|---|---|---|
| | | ២០១៥ | ២០១៦ | ២០១៧ |
| គម្រោង | ចំនួន | 31 | 28 | 25 |
| បង្កើតការងារ | ការងារ | 29,069 | 26,692 | 21,220 |
| ទុនវិនិយោគលើវិស័យ | | | | |
| កសិកម្ម | លានដុល្លារ | 27 | 247 | 0 |
| ឧស្សាហកម្ម | លានដុល្លារ | 346 | 113 | 120 |
| សេវាកម្ម | លានដុល្លារ | 100 | 91 | 0 |
| ទេសចរណ៍ | លានដុល្លារ | 38 | 56 | 0 |
| សរុប | លានដុល្លារ | 511 | 507 | 120 |

ប្រភព: ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

*រូបភាព 7 ÷ ចំនួនគម្រោង និងទុនវិនិយោគ (គិតជាលានដុល្លារអាមេរិក)*




ប្រភព: ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

## ២.៤. វិស័យទេសចរណ៍

*តារាង 14÷ ចំនួនអ្នកដំណើរឆ្លងកាត់ប្រទេសកម្ពុជា (គិតជាពាន់នាក់)*

| សូចនាករ | ត្រីមាសទី៤ | | |
|---|---|---|---|
| | ២០១៥ | ២០១៦ | ២០១៧ |
| សរុប | 1,428 | 1,503 | 1,689 |
| តាមផ្លូវអាកាស | 681 | 797 | 929 |
| ភ្នំពេញ | 284 | 330 | 383 |
| សៀមរាប | 397 | 450 | 522 |
| កងកេង | | 18 | 24 |
| តាមផ្លូវគោក និង ផ្លូវទឹក | 747 | 706 | 760 |
| ផ្លូវគោក | 700 | 668 | 723 |
| ផ្លូវទឹក | 47 | 38 | 37 |
| តាមប្រភេទ | 1,428 | 1,503 | 1,689 |
| អ្នកទេសចរ | 1,281 | 1,344 | 1,543 |
| អ្នកជំនួញ | 81 | 87 | 91 |
| ផ្សេងៗ | 67 | 73 | 55 |

ប្រភព: ក្រសួងទេសចរណ៍

*រូបភាព 8÷ កំណើនអ្នកដំណើរឆ្លងកាត់ប្រទេសកម្ពុជា (គិតជា %)*







ប្រភព: ក្រសួងទេសចរណ៍

## ២.៩. វិស័យសំណង់

*តារាង 15 ÷ គម្រោងអនុញ្ញាតសាងសង់*

| | ឯកត្តា | ត្រីមាសទី៤ | | |
|---|---|---|---|---|
| | | ២០១៥ | ២០១៦ | ២០១៧ |
| **សំណើសុំសាងសង់** | | | | |
| គម្រោង | ចំនួន | 565 | 627 | 896 |
| ក្រឡាផ្ទៃ | ម$^2$ | 3,186,700 | 2,350,818 | 2,238,338 |
| តម្លៃសាងសង់ | លានដុល្លារ | 1,587 | 974 | 1,163 |
| **សំណើសុំសាងសង់តាមប្រភេទ** | | | | |
| សំណង់សាធារណៈ | ម$^2$ | 6,065 | 9,079 | 28,217 |
| លំនៅដ្ឋាន និងភូមិគ្រឹះ | ម$^2$ | 1,476,922 | 1,600,050 | 873,178 |
| សំណង់ឧស្សាហកម្ម | ម$^2$ | 1,104,600 | 575,213 | 373,963 |
| សំណង់ពាណិជ្ជកម្ម | ម$^2$ | 506,987 | 153,044 | 884,234 |
| សំណង់ទេសចរណ៍ | ម$^2$ | 92,126 | 12,656 | 77,814 |
| សំណង់វិនិយោគផ្សេងៗ | ម$^2$ | 0 | 777 | 933 |
| **សរុប** | ម$^2$ | 3,186,700 | 2,350,819 | 2,238,338 |

ប្រភព: ក្រសួងរៀបចំដែនដី នគររូបនីយកម្ម និងសំណង់

*រូបភាព 9 ÷ សំណើសុំវិនិយោគសាងសង់ គិតជាក្រឡាផ្ទៃ ចែកតាមប្រភេទសំណង់*




ប្រភព: ក្រសួងរៀបចំដែនដី នគររូបនីយកម្ម និងសំណង់

## ៣. ថ្លៃទំនិញសំខាន់ៗ និងអត្រាប្តូរប្រាក់លើទីផ្សារអន្តរជាតិ

*តារាង 16 ÷ ថ្លៃទំនិញប្រើប្រាស់លើទីផ្សារអន្តរជាតិ (គិតជាដុល្លារអាមេរិក)*

| មុខទំនិញ | ឯកតា | ទីផ្សារ | ត្រីមាសទី៤ | | |
|---|---|---|---|---|---|
| | | | ២០១៥ | ២០១៦ | ២០១៧ |
| អង្ករ | តោន/ ដុល្លារ | បាងកក | 363 | 373 | 389 |
| ប្រេងឆៅ Brent | ធុង/ ដុល្លារ | ក្រុងឡុង | 38 | 54 | 64 |
| កៅស៊ូ | តោន/ ដុល្លារ | សឹង្ហបុរី | 1,248 | 1,930 | 1,652 |
| មាស | អោន/ ដុល្លារ | ហុងកុង | 974 | 1,157 | 1,387 |
| ពោតក្រហម | តោន/ ដុល្លារ | ស៊ីកាហ្គោ | 164 | 152 | 149 |
| សណ្តែកសៀង | តោន/ ដុល្លារ | ស៊ីកាហ្គោ | 379 | 421 | 398 |
| ប្រេងដូង | តោន/ ដុល្លារ | រ៉ូតធើឌាំ | 1,150 | 1,684 | 1,443 |
| ស្ករស | តោន/ ដុល្លារ | ក្រុងឡុង | 355 | 340 | 387 |

ប្រភព: គេហទំព័រធនាគារពិភពលោក

*រូបភាព 10 ÷ ថ្លៃជីកសិកម្មលើទីផ្សារអន្តរជាតិ (គិតជាដុល្លារអាមេរិក/ម៉ែត្រទ្រីកតោន)*




ប្រភព: គេហទំព័រធនាគារពិភពលោក (http://www.worldbank.org/en/research/commodity-markets)

*តារាង 17 ÷ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់លើទីផ្សារអន្តរជាតិ (ឆ្នាំគោល ២០១០=១០០)*

| មុខទំនិញ | ត្រីមាសទី៤ | | |
|---|---|---|---|
| | ២០១៥ | ២០១៦ | ២០១៧ |
| ប្រេងឥន្ធនៈ | 37 | 53 | 61 |
| ផលិតផលកសិកម្ម | 85 | 89 | 87 |
| ម្ហូបអាហារ | 86 | 93 | 91 |
| ឈើ | 94 | 83 | 88 |
| ជីគីមី | 91 | 61 | 72 |

ប្រភព: គេហទំព័រធនាគារពិភពលោក (http://www.worldbank.org/en/research/commodity-markets)

*រូបភាព 11 ÷ សន្ទស្សន៍ថ្លៃមុខទំនិញសំខាន់ៗលើទីផ្សារអន្តរជាតិ*




ប្រភព: គេហទំព័រធនាគារពិភពលោក (http://www.worldbank.org/en/research/commodity-markets)

*តារាង 18 ÷ អត្រាប្តូរប្រាក់លើទីផ្សារអន្តរជាតិធៀបនឹងដុល្លារអាមេរិក (មធ្យមប្រចាំត្រីមាស)*

| រូបិយប័ណ្ណ | ត្រីមាសទី៤ | | |
|---|---|---|---|
| | ២០១៥ | ២០១៦ | ២០១៧ |
| ជប៉ុន (យ៉េន) | 120.49 | 116.72 | 112.65 |
| ហុងកុង (ដុល្លារ) | 7.75 | 7.75 | 7.81 |
| សឹង្ហបុរី (ដុល្លារ) | 1.41 | 1.45 | 1.34 |
| ម៉ាឡេស៊ី (រីងហ្គីត) | 4.29 | 4.48 | 4.06 |
| ហ្វីលីពីន (ប៉េសូ) | 46.85 | 49.48 | 49.90 |
| ថៃ (បាត) | 36.00 | 35.76 | 32.55 |
| ឥណ្ឌូនេស៊ី (រូព្យា) | 13,793.10 | 13,440.90 | 13,544.40 |
| កូរ៉េ (វ៉ូន) | 1,173.02 | 1,203.51 | 1,066.24 |
| តៃវ៉ាន់ (ដុល្លារ) | 32.89 | 32.32 | 29.66 |
| ចិន (រ៉េនមីនប៊ី) | 6.49 | 6.95 | 6.52 |
| កម្ពុជា (រៀល) | 4,050.00 | 3,928.39 | 4,008.68 |
| ឡាវ (គីប) | 7,997.05 | 7,908.57 | 8,238.79 |
| វៀតណាម (ដុង) | 22,108.70 | 22,437.90 | 22,640.30 |
| ឥណ្ឌា (រូពី) | 66.20 | 67.84 | 63.71 |
| រុស្ស៊ី (រូប) | 73.16 | 60.80 | 57.61 |
| អូស្ត្រាលី (ដុល្លារ) | 1.37 | 1.38 | 1.28 |
| មិចស៊ិចកូ (ប៉េសូ) | 17.29 | 20.67 | 19.68 |
| អង់គ្លេស (ផោន) | 0.67 | 0.81 | 0.74 |
| ស្វីស (ហ្វ្រង់) | 0.99 | 1.02 | 0.98 |
| អឺរ៉ុប (អឺរ៉ូ) | 0.92 | 0.95 | 0.83 |

ប្រភព: OANDA (Internet)

# ឧបសម្ព័ន្ធ

*តារាង 19 ÷ ស្ថិតិហិរញ្ញវត្ថុរដ្ឋាភិបាល (GFS)*

| លានរៀល | ត្រីមាសទី៤ | | |
|---|---|---|---|
| | ២០១៥ | ២០១៦ | ២០១៧ |
| ចំណូល | 2,948,794 | 3,983,325 | 2,696,767 |
| ពន្ធ | 2,387,690 | 2,796,015 | 2,050,917 |
| អំណោយ | 157,730 | 519,730 | 126,647 |
| ចំណូលពន្ធផ្សេងទៀត | 403,373 | 667,580 | 519,202 |
| ចំណាយ | 2,999,728 | 4,089,637 | 2,374,203 |
| បន្ទុកបុគ្គលិក | 954,333 | 1,368,189 | 1,045,811 |
| ទំនិញ និងសេវាកម្ម | 1,030,651 | 1,404,633 | 514,443 |
| ការប្រាក់ | 23,547 | 38,841 | 22,963 |
| ឧបត្ថម្ភធន | 0 | 0 | 154,476 |
| អំណោយ | 386,879 | 416,633 | 183,975 |
| ឧបត្ថម្ភសង្គមកិច្ច | 371,780 | 448,794 | 308,462 |
| ចំណាយផ្សេងៗ | 232,538 | 412,546 | 144,075 |
| តុល្យភាពប្រតិបត្តិការដុល | (50,934) | (106,311) | 322,564 |
| តុល្យភាពប្រតិបត្តិការសុទ្ធ | (50,934) | (106,311) | 322,564 |
| ទ្រព្យមិនមែនហិរញ្ញវត្ថុសុទ្ធ | 1,323,308 | 1,941,110 | 851,568 |
| ទ្រព្យអចលកម្ម | 1,241,671 | 1,941,110 | 851,568 |
| ទ្រព្យគ្មានផលិតភាព | 81,637 | 0 | 0 |
| ចំណាយសរុប | 4,323,036 | 6,030,747 | 3,225,770 |
| *កម្ចី/បំណុលសុទ្ធ (១)-(២)-(៣)* | (1,374,242) | (2,047,422) | (529,004) |
| ទ្រព្យហិរញ្ញវត្ថុសុទ្ធ | (704,936) | (683,381) | (283,969) |
| ក្នុងប្រទេស | (704,936) | (683,381) | (283,969) |
| បំណុល | 680,968 | 1,360,733 | 245,034 |
| ក្នុងប្រទេស | 114,912 | 688,632 | 0 |
| ក្រៅប្រទេស | 566,056 | 672,101 | 245,034 |

ប្រភព៖ អគ្គនាយកដ្ឋានគោលនយោបាយ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## *តារាង 20 ÷ ស្ថិតិកសិកម្ម*

| ផលិតកម្មកសិកម្ម និងនាំចេញ | ឯកតា | ត្រីមាសទី៤ | | |
|---|---|---|---|---|
| | | ២០១៥ | ២០១៦ | ២០១៧ |
| **ផ្ទៃដីដាំដុះ** | | | | |
| ស្រូវ | ហិកតា | 2,981,552 | 2,907,087 | 2,989,631 |
| ដំណាំរួមផ្សំ និងដំណាំឧស្សាហកម្ម | ហិកតា | 913,108 | 963,001 | 953,053 |
| កៅស៊ូ | ហិកតា | 357,137 | 431,053 | 436,338 |
| **ផ្ទៃដីប្រមូលផល** | | | | |
| ស្រូវ | ហិកតា | 2,536,197 | 2,315,794 | 2,382,929 |
| កៅស៊ូ | ហិកតា | 109,130 | 126,996 | 170,232 |
| **បរិមាណផល** | | | | |
| ស្រូវ | តោន | 6,249,409 | 6,857,807 | 7,184,906 |
| កៅស៊ូ (ក្រែប) | តោន | 126,861 | 127,852 | 193,285 |
| ជលផល | តោន | 751,546 | 802,450 | 856,263 |
| **នាំចេញ** | | | | |
| អង្ករ | តោន | 521,275 | 525,829 | 573,441 |
| ស្រូវ | តោន | 0 | 0 | 2,485 |
| កៅស៊ូ | តោន | 127,876 | 125,962 | 157,304 |
| ស្ករ | តោន | 0 | 0 | 130,001 |
| ផលិតផលជលផល | តោន | 190 | 214 | 340 |
| ផលិតផលកសិកម្មផ្សេងៗ | តោន | 119,725 | 88,190 | 218,641 |

ប្រភពៈ របាយការណ៍ប្រចាំសប្តាហ៍ ប្រចាំខែ និងប្រចាំឆ្នាំ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
របាយការណ៍ពាណិជ្ជកម្មប្រចាំខែ

## កំណត់សម្គាល់បច្ចេកទេស

| | |
|---|---|
| **មុខទំនិញនិងសេវាលើទីផ្សារភ្នំពេញ** | មុខទំនិញទាំងអស់ ត្រូវបានចែកចេញជា ១០ ក្រុម រួមមាន សម្ភារការិយាល័យ សម្ភារសំណង់ គ្រឿងសង្ហារឹម ឧបករណ៍អេឡិចត្រូនិច សម្ភារបរិក្ខារអគ្គិសនី សម្ភារប្រើប្រាស់និងសម្អាត សម្ភារប្រើប្រាស់ផ្សេងៗ យានយន្តនិងគ្រឿងបន្លាស់ ថ្នាំពេទ្យនិងបរិក្ខារពេទ្យ និងសំបុត្រយន្តហោះ។ |
| **ចំណូល (ស្ថិតិហិរញ្ញវត្ថុរដ្ឋាភិបាល)** | ជាប្រតិបត្តិការ ដែលធ្វើឱ្យតម្លៃទ្រព្យសកម្មសុទ្ធកើនឡើង។ ប្រតិបត្តិការចំណូលនៅក្នុងស្ថិតិហិរញ្ញវត្ថុរដ្ឋាភិបាល អាចធ្វើឱ្យមានការកើនឡើងនៃទ្រព្យ ឬការថយចុះនៃបំណុល និងអាចឱ្យមានការប្រែប្រួលកំណើននៃតំលៃទ្រព្យសកម្មសុទ្ធ។ |
| **ចំណាយ (ស្ថិតិហិរញ្ញវត្ថុរដ្ឋាភិបាល)** | គឺជាប្រតិបត្តិការ ដែលធ្វើឱ្យតម្លៃទ្រព្យសកម្មសុទ្ធថយចុះ។ ប្រតិបត្តិការចំណាយក្នុងស្ថិតិហិរញ្ញវត្ថុរដ្ឋាភិបាល ធ្វើឱ្យមានផលប៉ះពាល់ពីរធំៗ រួមមាន ការថយចុះនៃទ្រព្យឬការកើនឡើងនៃបំណុល។ |

*រៀបចំដោយនាយកដ្ឋានស្ថិតិ និងវិភាគសេដ្ឋកិច្ច នៃអគ្គនាយកដ្ឋានគោលនយោបាយ*

*ទំនាក់ទំនង:* *(855) 12 997 616*
*(855) 89 898 878*